ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ
អគ្គលេខាធិការដ្ឋាន

លេខ: ២៣/២០១៥ អ.កបធ.សជណ

# សេចក្តីប្រកាសព័ត៌មាន

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅថ្ងៃអង្គារ ទី២៤ខែមីនា ឆ្នាំ២០១៥ ចាប់ពីម៉ោង ១១:០០ ព្រឹក នៅទីស្តីការក្រុមប្រឹក្សាធម្មនុញ្ញ អគារ "**ស**" នៃវិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម ខណ្ឌចំការមន រាជធានីភ្នំពេញ មានបើកកិច្ចប្រជុំពេញអង្គក្រោមអធិបតីភាពរបស់ឯកឧត្តម **ឯក សំអុល** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញដើម្បីពិនិត្យ និង សម្រេចលើ ៖

១-សំណើលេខ ២៦១ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

២-សំណើលេខ ២៦២ រ.ស ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ របស់**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំពិនិត្យធម្មនុញ្ញភាពលើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ។

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៥

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ: (៨៥៥) ២៣ ៧២៦ ០៣១, E-mail: sgccc@online.com.kh / info@ccc.gov.kh, Website :http://www.ccc.gov.kh,ប្រអប់សំបុត្រ ២៤៨៣ ភ្នំពេញ